ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៧០ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៧.៥00 ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះកាត់ចេញពីដីរបស់រដ្ឋ( អតីតដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន លាង ហួហុង និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកៅឆ្លែ ) និងពីព្រៃសម្បទានព្រៃឬស្សី ក្រុមហ៊ុន តាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីភ្នំ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥៦២ ខបប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់ គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១៦៩៨ ខបប ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ដីសរុបទំហំ ៧.៥០០ ហិកតា ដែលក្នុងនោះ ទំហំ ៧.២៩២ ហិកតា កាត់ចេញពីដីរបស់រដ្ឋ(អតីតដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន លាង ហ្វូហុង និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកៃឆ្វៃ) និងទំហំ ២០៨ ហិកតា ចេញពីព្រៃសម្បទានព្រៃឬស្សី ក្រុមហ៊ុន ភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៧.៤៦៦,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.១៥៧ គ្រួសារ និង ៣៣,៥ ហិកតា រក្សាទុកជាដីភ្នំ នៅស្រុកកំរៀង ខេត្តបាត់ដំបង ដែលស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម៖

១. ផ្ទៃដីទំហំ ៣៧៣.៥ ហិកតា កាត់ចេញពីដីរបស់រដ្ឋ(អតីតដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន លាង ហ្វូហុង និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកៃឆ្វៃ) សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិសាមសិប ឃុំតាក្រី

២. ផ្ទៃដីសរុបទំហំ ១.៨៧៧,៥ ហិកតា ក្នុងនោះ ទំហំ ១.៨៧១,៥ ហិកតា កាត់ចេញពីដីរបស់រដ្ឋ(អតីតដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន លាង ហ្វូហុង និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១៥៥ គ្រួសារ នៅភូមិសាមសិប ឃុំតាគ្រី
- ប្រទានជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៦៥៥ គ្រួសារ នៅភូមិ កំពង់ចម្លងលើ ឃុំតាគ្រី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១៩៣ គ្រួសារ នៅភូមិ ម្ចាស់កាល់ ឃុំអូរដា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៩៥៣ គ្រួសារ នៅភូមិ កំពង់ឡី ឃុំអូរដា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៥៩៧ គ្រួសារ នៅភូមិ សំពោង ឃុំអូរដា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៧៦ គ្រួសារ នៅភូមិថ្មី ឃុំអូរដា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២៨ គ្រួសារ នៅភូមិកណ្តាល ឃុំអូរដា ។

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ១.២២៣ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១.២១៨ ក្បាលដី ជូនប្រជាពលរដ្ឋ ៨០៩ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងដីរដ្ឋ ០៤ ក្បាលដី (ដីសម្រាប់សាងសង់សាលារៀន ០៣ ក្បាលដី និងដីស្រះទឹក ០១ ក្បាលដី) នៅក្នុងឃុំតាគ្រី ស្រុកកំរៀង ដែលក្នុងនោះ ផ្តល់ជា៖

- កម្មសិទ្ធិលើក្បាលដីសរុបចំនួន ២២៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដី ២២៤ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៥៥ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងដីសម្រាប់សាងសង់សាលារៀន ០១ ក្បាលដី នៅភូមិសាមសិប

- កម្មសិទ្ធិលើក្បាលដីសរុបចំនួន ៩៩៧ ក្បាលដី ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដី ៩៩៤ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៦៥៤ គ្រួសារ និងដីរដ្ឋ ០៣ ក្បាលដី (ដីសម្រាប់សាងសង់សាលារៀន ០២ ក្បាលដី និងដីស្រះទឹក ០១ ក្បាលដី)នៅ ភូមិកំពង់ចម្លងលើ

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៩ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*